**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ៥០/២០២៦ កបទ.សអ

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម **អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋបារាំង ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦។

នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ក្នុងអំឡុងជំនួបទ្វេភាគីជាមួយ **ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង** នៅវិមានអេលីហ្សេ ( Élysée) **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអបអរសាទរឯក**ឧត្តមប្រធានាធិបតី** ចំពោះភាពជោគជ័យដែលបារាំងបានធ្វើជាម្ចាស់ផ្ទះរៀបចំ "**កិច្ចប្រជុំកំពូលស្តីពីសុខភាពតែមួយ**" និងបានថ្លែងអំណរគុណចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្តៅជូន **សម្តេចធិបតី** និងគណៈប្រតិភូកម្ពុជា។ កិច្ចប្រជុំបានប្រព្រឹត្តទៅប្រកបដោយបរិយាកាសស្និទ្ធស្នាល និងស្តាបនាដែលឆ្លុះបញ្ចាំងអំពីមិត្តភាពដ៏យូរអង្វែង និងការជឿទុកចិត្តគ្នារវាងប្រទេសទាំងពីរ ដូចដែលបានគូសបញ្ជាក់តាមរយៈការផ្លាស់ប្តូរទស្សនកិច្ច និងកិច្ចសន្ទនាកម្រិតខ្ពស់ជាច្រើនជាមួយគ្នាទៅវិញទៅមក មានដូចជា ជំនួបរវាងរដ្ឋមន្ត្រីការបរទេសទាំងពីរនៅក្រសួងការបរទេសបារាំង ការសម្ពោធ "**សួនឧទ្យាន នរោត្តម សីហនុ**" នៅហ្វៀអង់តាដឺណ័រ កាលពីដើមឆ្នាំនេះ ហើយនិងការរៀបចំកិច្ចប្រជុំកិច្ចពិគ្រោះយោបល់ផ្នែកនយោបាយទ្វេភាគីជាប្រចាំ។

ថ្នាក់ដឹកនាំទាំងពីរបានគូសបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីលើកតម្កើងទំនាក់ទំនងទ្វេភាគីឲ្យទៅជាដៃគូយុទ្ធសាស្ត្រនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខ និងបានសង្កត់ធ្ងន់លើសន្ទុះនៃភាពខ្លាំង និងវឌ្ឍនភាពនៃទំនាក់ទំនងរវាងប្រទេសកម្ពុជា និងបារាំងដែលគាំទ្រដោយវិស័យកិច្ចសហប្រតិបត្តិការជាច្រើន មានដូចជា ពាណិជ្ជកម្ម និងការវិនិយោគ, ការពារជាតិ និងសន្តិសុខ, អប់រំ, សុខភាពសាធារណៈ, ការការពារបតិកកណ្ឌវប្បធម៌, ការគាំទ្រថាមពលកកើតឡើងវិញ ភាពធន់ទៅនឹងអាកាសធាតុ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន។ **សម្តេចធិបតី** ក៏បានសម្តែងនូវការពេញចិត្តចំពោះវិភាគទានដ៏មានតម្លៃ និងយូរអង្វែងរបស់បារាំងចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ជាពិសេសតាមរយៈភ្នាក់ងារអភិវឌ្ឍន៍ របស់ប្រទេសបារាំង។

ភាគីទាំងពីរបានស្វាគមន៍ការបន្តពង្រីកចំណងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច តាមរយៈកំណើនទំហំពាណិជ្ជកម្ម និងការកើនឡើងជាលំដាប់នៃលំហូរក្នុងវិស័យទេសចរណ៍រវាងប្រទេសទាំងពីរ និងក៏បានកត់សម្គាល់អំពីគម្រោងសហប្រតិបត្តិការដែលកំពុងដំណើរការ និងនាពេលអនាគត ជា

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែលៈ mfaic@mfaic.gov.kh

ពិសេសនៅក្នុងវិស័យថាមពល គំនិតផ្តួចផ្តើមគ្រប់គ្រងកាកសំណល់ និងវិស័យដែលកំពុងលេចឡើង ដូចជា បញ្ញាសិប្បនិម្មិត និងវិទ្យាសាស្ត្រទិន្នន័យ ដែលត្រូវបានគេរំពឹងថានឹងជួយពង្រឹងបន្ថែមទៀតនូវកំណើនដែលជំរុញដោយនវានុវត្តន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ថ្នាក់ដឹកនាំទាំងពីរបានរំលេចពីវឌ្ឍនភាពជាលំដាប់លើកិច្ចសហប្រតិបត្តិការក្នុងវិស័យការពារជាតិ និងសន្តិសុខ រួមមាន ការគាំទ្រលើការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពដល់កងកម្លាំងថែរក្សាសន្តិភាពកម្ពុជា ហើយនិងការពង្រឹងការផ្លាស់ប្តូររវាងស្ថាប័នពាក់ព័ន្ធ។ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការបន្តកិច្ចសហការលើវិស័យអប់រំ និងការអភិវឌ្ឍធនធានមនុស្ស រួមមាន អាហារូបករណ៍ ការបណ្តុះបណ្តាលបច្ចេកទេស និងភាពជាដៃគូលើផ្នែកអប់រំ។ ក្នុងវិស័យវប្បធម៌ ភាគីទាំងពីរបានស្វាគមន៍ចំពោះកិច្ចសហប្រតិបត្តិការអភិរក្សសម្បត្តិបេតិកភណ្ឌ និងការអភិវឌ្ឍសារមន្ទីរដែលបន្តពង្រឹងទំនាក់ទំនងផ្នែកវប្បធម៌ និងប្រវត្តិសាស្ត្ររវាងកម្ពុជា និងបារាំង។

ក្នុងជំនួបនេះ **សម្តេចធិបតី**បានជម្រាប**ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង** អំពីការធ្វើជាម្ចាស់ផ្ទះរបស់កម្ពុជាក្នុងការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នាខែវិច្ឆិកា ឆ្នាំ២០២៦ នៅភ្នំពេញ ក្រោមមូលបទ "ការវិនិយោគឡើងវិញលើសន្តិភាពដើម្បីវិបុលភាពរួម និងស្ថិរភាពជានិរន្តរ៍"។ **សម្តេចធិបតី**បានគូសបញ្ជាក់ពីមហិច្ឆតារបស់កម្ពុជាក្នុងការពង្រឹងតួនាទីរបស់ហ្វ្រង់កូហ្វូនីនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកយុវជន នវានុវត្តន៍ និងសេដ្ឋកិច្ច។ **សម្តេចធិបតី**រង់ចាំទទួលស្វាគមន៍**ឯកឧត្តមប្រធានាធិបតីបារាំង**មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ និងចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី ២០ នៅកម្ពុជា ដែលទស្សនកិច្ចជាប្រវត្តិសាស្ត្រនេះនឹងផ្តល់សន្ទុះបន្ថែមដល់ការពង្រឹងទំនាក់ទំនងឲ្យកាន់តែស៊ីជម្រៅលើផ្នែកយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ។

ថ្នាក់ដឹកនាំប្រទេសទាំងពីរបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះពហុភាគីនិយម និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ។ ភាគីទាំងពីរបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិ ការលើកកម្ពស់ការដោះស្រាយជម្លោះដោយសន្តិវិធី និងការរក្សាសណ្តាប់ធ្នាប់ពិភពលោកដែលផ្អែកលើច្បាប់។ ក្នុងន័យនេះ **សម្តេចធិបតី** បានជម្រាបជូន**ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង** អំពីការកាន់កាប់ទឹកដីកម្ពុជាដោយយោធាថៃ និងសកម្មភាពរបស់យោធាថៃនៅលើដីផ្ទាល់ដែលផ្លាស់ប្តូរស្ថានភាពដើម ក្នុងគោលដៅបង្កើតឱ្យមាននូវស្ថានភាពបង្ខំឲ្យទទួលយកនូវអ្វីដែលកើតមាន។ **សម្តេចធិបតី**បានគូសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដ៏មុតមាំរបស់កម្ពុជាក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី ដោយគ្មានការប្រើប្រាស់កម្លាំង ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន និងគោរពតាមសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់។

**ឯកឧត្តមប្រធានាធិបតីអេម៉ានុយអែល ម៉ាក្រុង** បានថ្លែងអំណរគុណចំពោះ**សម្តេចធិបតី** ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលស្តីពីសុខភាពតែមួយ នៅទីក្រុងលីយ៉ុង ដោយកត់សម្គាល់ថាវត្តមានរបស់កម្ពុជាឆ្លុះបញ្ចាំងការប្តេជ្ញាចិត្តដ៏ខ្លាំងក្លាចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការលើកកម្ពស់អភិក្រមសុខភាពតែមួយ។

**ឯកឧត្តមប្រធានាធិបតីបារាំង**បានស្វាគមន៍ចំពោះសន្ទុះដ៏វិជ្ជមាននៃទំនាក់ទំនងទ្វេភាគី និងបានសម្ដែងការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងប្រទេសទាំងពីរ លើវិស័យអាទិភាពជាច្រើន រួមមាន ថាមពល វប្បធម៌ សុខាភិបាល អប់រំ កសិកម្ម និងការពារជាតិ។ **ឯកឧត្តមប្រធានាធិបតី**បានគូសបញ្ជាក់ការរួមចំណែកដ៏សំខាន់របស់ក្រុមហ៊ុនបារាំងដែលដំណើរការនៅកម្ពុជា ជាពិសេស Vinci Group និងក្រុមហ៊ុនតូតាល់ ដែលគួរឱ្យកត់សម្គាល់ក្នុងវិស័យថាមពលស្អាត និងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព។

**ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង** បានបញ្ជាក់បន្ថែមអំពីការគាំទ្រដ៏មុតមាំរបស់បារាំងចំពោះការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី ២០ និងបានបញ្ជាក់ពីការត្រៀមខ្លួនរួចរាល់ក្នុងការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយកម្ពុជាដើម្បីធានាដល់ជោគជ័យនៃព្រឹត្តិការណ៍ដ៏សំខាន់នេះ។

ពាក់ព័ន្ធបញ្ហាព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង**បានបញ្ជាក់ថា បារាំងបាន និងកំពុងតាមដានស្ថានការណ៍នេះយ៉ាងយកចិត្តទុកដាក់ និងលើកទឹកចិត្តឱ្យភាគីទាំងពីរដោះស្រាយជម្លោះនេះតាមរយៈមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និងសន្ធិសញ្ញាដែលពាក់ព័ន្ធ។ **ឯកឧត្តមប្រធានាធិបតី**បានបញ្ជាក់សាជាថ្មីពីការប្រកាន់ដ៏រឹងមាំនូវគោលការណ៍អធិបតេយ្យភាព និងបូរណភាពទឹកដី។ ក្នុងន័យនេះ **ឯកឧត្តមប្រធានាធិបតី**បានបញ្ជាក់ជាថ្មីពីការត្រៀមខ្លួនរួចរាល់របស់រដ្ឋាភិបាលបារាំងក្នុងការសម្របសម្រួលការចូលទៅយកឯកសារបច្ចេកទេស និងប្រវត្តិសាស្ត្រពាក់ព័ន្ធព្រំដែនអន្តរជាតិរវាងកម្ពុជា និងថៃ ក្នុងទស្សនៈគាំទ្រការដោះស្រាយបញ្ហានេះដោយសន្តិវិធី។

ក្នុងអំឡុងទស្សនកិច្ចនេះ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ នៅទីក្រុងលីយ៉ុង **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលស្ដីពីសុខភាពតែមួយ ដែលជាវេទិកាជួបជុំប្រមុខរដ្ឋ/រដ្ឋាភិបាល រដ្ឋមន្ត្រី ប្រធានអង្គការអន្តរជាតិ អ្នកវិទ្យាសាស្ត្រ និងសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងសុខភាពមនុស្ស សត្វ និងបរិស្ថាន។ កិច្ចប្រជុំកំពូលនេះបានអនុម័តដំណោះស្រាយសំខាន់ៗ មួយចំនួន ដើម្បីគូសបញ្ជាក់អំពីការប្ដេជ្ញាចិត្តក្នុងការជំរុញអភិក្រមសុខភាពតែមួយ និងពង្រឹងកិច្ចសហប្រតិបត្តិការសាកលក្នុងការដោះស្រាយបញ្ហារួមនេះ។

ក្នុងកិច្ចប្រជុំកំពូលនេះ **សម្ដេចធិបតី** បានថ្លែងបទអន្តរាគមន៍ស្ដីពីជំងឺឆ្លង ដោយបានរំលេចនូវជោគជ័យរបស់កម្ពុជាក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ ទាំងក្នុងដំណាក់ទប់ស្កាត់យ៉ាងតឹងរ៉ឹង ទាំងក្នុងដំណាក់កាលស្ដារប្រទេសឡើងវិញដោយមានការចាក់វ៉ាក់សាំងបានទូលំទូលាយ។ **សម្ដេចធិបតី**បានទាញចំណាប់អារម្មណ៍ចំពោះបញ្ហាប្រឈមដែលកំពុងកើតមាន រួមមាន ជំងឺផ្ដាសាយបក្សី ការកើនឡើងនៃភាពធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិក (AMR), និងហានិភ័យសុខភាពបណ្ដាលមកពីអាកាសធាតុ ដែលជំរុញបន្ថែមដោយកត្តាមួយចំនួនដូចជា បម្លាស់ទីបក្សីព្រៃ ការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ និងការសឹករេចរិលនៃបរិស្ថាន។ **សម្ដេចធិបតី** បានគូសបញ្ជាក់ថា ចំពោះបញ្ហាសន្តិសុខសុខភាពត្រូវធ្វើការងារជាសាកលរួមគ្នា ហេតុនេះ **សម្ដេចធិបតី** បានលើកនូវចំណុចអាទិភាពចំនួន ៥ រួមមាន (១) ការពង្រឹងភាពជាដៃគូ និងសាមគ្គីភាព (២) ការបង្កើនការធ្វើសមាហរណកម្មឃ្លាំមើល និងការផ្ដល់ដំណឹងឱ្យដឹងមុន (៣) ការគៀងគរមូលនិធិ និងនវានុវត្តន៍ឲ្យមានចីរភាព (៣). ការប្រយុទ្ធប្រឆាំងនឹងភាពធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិក និងការប្រែប្រួលសម្ពាធបរិយាកាស និង (៥). ការលើកកម្ពស់ចំណេះដឹងសមធម៌ និងការត្រៀមខ្លួនជាមុន។

នៅមុនកិច្ចប្រជុំកំពូល **សម្តេចធិបតី** បានអញ្ជើញចូលរួមកិច្ចប្រជុំចង្អៀតស្តីពីនិម្មាបនកម្មសុខភាពសកល ក្រោមអធិបតីភាព**ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង** ដែលបានអនុម័តសេចក្តីប្រកាសនយោបាយរួមស្តីពីការកែទម្រង់និម្មាបនកម្មសុខភាពសកល (សេចក្តីប្រកាសទីក្រុងលីយ៉ុង)។ នៅក្នុងបទអន្តរាគមន៍ **សម្តេចធិបតី** បានរំលេចអំពីបញ្ហាប្រឈមនៃសុខភាពសកលដែលមានភាពស្មុគស្មាញ និងផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួត រួមមាន ជំងឺឆ្លងពីសត្វ និងភាពធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិក ព្រមទាំងការរេចរឹលនៃបរិស្ថាន និងហានិភ័យផ្នែកសុវត្ថិភាពចំណីអាហារ និងបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃអភិក្រមសុខភាពតែមួយ។ **សម្តេចធិបតី** បានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងប្រព័ន្ធសុខភាពជាតិ តាមរយៈការថែទាំសុខភាពបឋម និងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសុខភាពតែមួយឆ្នាំ២០២៥-២០២៩។ **សម្តេចធិបតី** បានសង្កត់ធ្ងន់ផងដែរពីតម្រូវការនៃការមានសំឡេងតែមួយប្រឆាំងនឹងការយកបញ្ហាសុខាភិបាលធ្វើជាបញ្ហានយោបាយ ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ និងកៀរគរកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ធានាការចែករំលែកព័ត៌មានឱ្យទាន់ពេលវេលា និងសម្របសម្រួលការឆ្លើយតបដែលស៊ីសង្វាក់គ្នាតាមរយៈការវិនិយោគលើប្រព័ន្ធឃ្លាំមើល និងប្រព័ន្ធជូនដំណឹងជាមុន។

ក្នុងឱកាសនោះ **សម្តេចធិបតី** បានជួបជាមួយឯកឧត្តម Duma Gideon Boko ប្រធានាធិបតីបុតស្វាណា ឯកឧត្តម John Dramani Mahama ប្រធានាធិបតីហ្គាណា ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Khaled El Enany អគ្គនាយកអង្គការយូណេស្កូ និងឯកឧត្តម Akihiko Nishio អនុប្រធានធនាគារពិភពលោក។

ដំណើរទស្សនកិច្ចនេះគូសបញ្ជាក់នូវភាពជាដៃគូកាន់តែស៊ីជម្រៅរវាងកម្ពុជា និងបារាំង និងការប្តេជ្ញាចិត្តរួមក្នុងបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីជាផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជនទាំងពីរ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព ស្ថិរភាព និងសន្តិភាពនៅក្នុងតំបន់ និងពិភពលោក៕

ថ្ងៃព្រហស្បតិ៍ ៧រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦